ក្រុមប្រឹក្សាយុវជនកម្ពុជា
Youth Council of Cambodia

# គោលនយោបាយ ការពារកុមារ

# Child Protection Policy

ឆ្នាំ ២០១៤

សំរាប់ប្រើប្រាស់ផ្ទៃក្នុង
For Internal Use Only

# មាតិកា


១. សេចក្តីណែនាំ ........ ០១
២. សេចក្តីថ្លែងការណ៍គោលនយោបាយ ........ ០១
៣. ការរំលោភបំពានកុមារ ........ ០១
៤. ការអនុវត្តគោលនយោបាយ ........ ០២
    ៤.១. សីលធម៌ផ្ទាល់របស់បុគ្គលិកក្រុមប្រឹក្សាយុវជនកម្ពុជា ........ ០២
    ៤.២ ការជ្រើសរើសបុគ្គលិក ........ ០៣
៥. ការបណ្តុះបណ្តាល ........ ០៣
៦. ការផ្សព្វផ្សាយ និងការទំនាក់ទំនង ........ ០៣
សេចក្តីថ្លែងការណ៍នៃការប្តេជ្ញាចិត្ត ........ ០៥

## ១. សេចក្តីណែនាំ

ដើម្បីការពារកុមារពីការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់បែបយ៉ាង អង្គការក្រុមប្រឹក្សាយុវជនកម្ពុជា ប្តេជ្ញានឹងធ្វើការលើកកម្ពស់សិទ្ធិកុមារ នឹងខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីការពារផលប្រយោជន៍ សិទ្ធិ និងជាសុកភាពរបស់កុមារទូទៅនៅក្នុងសហគមន៍កំពុងអភិវឌ្ឍន៍ ដូចបានចែងនៅក្នុងឆ្នាំ១៩៨៩ នៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ។

ក្រុមប្រឹក្សាយុវជនកម្ពុជា នឹងរៀបចំបែបបទផ្សេងៗ ការអនុវត្តទាំងឡាយដែលបានរៀបរៀងឡើងនៅក្នុងឯកសារច្បាប់នេះ ដើម្បីការពារកុមារពីការរំលោភបំពាន ការមិនយកចិត្តទុកដាក់ និងការកេងប្រវ័ញ្ចផលប្រយោជន៍របស់កុមារពីសមាជិកក្រុមប្រឹក្សាភិបាល ម្ចាស់ជំនួយ នាយក/នាយិកាប្រតិបត្តិ បុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកហាត់ការ បណ្តាញយុវជន និងក្លឹបយុវជន របស់ក្រុមប្រឹក្សាយុវជនកម្ពុជាទាំងអស់ អ្នកគាំទ្រ អ្នកពាក់ព័ន្ធ និងពីអ្នកតំណាងអង្គការណាមួយ ដែលមានទំនាក់ទំនងក្នុងការងារជាមួយក្រុមប្រឹក្សាយុវជនកម្ពុជា។

កិច្ចការពារកុមារទាំងអស់ គឺជាការទទួលខុសត្រូវ របស់អ្នកទាំងឡាយណាដែលបានចូលរួមនៅក្នុងដំណើរការការងារជាមួយក្រុមប្រឹក្សាយុវជនកម្ពុជា រួមមានសមាជិកក្រុមប្រឹក្សាភិបាល ម្ចាស់ជំនួយ នាយក/នាយិកាប្រតិបិត្តិ បុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកហាត់ការ បណ្តាញយុវជន និងក្លឹបយុវជនរបស់ក្រុមប្រឹក្សាយុវជនកម្ពុជាទាំងអស់ អ្នកគាំទ្រ និងអ្នកពាក់ព័ន្ធ។

## ២. សេចក្តីថ្លែងការណ៍គោលនយោបាយ

ច្បាប់ និងទម្រង់បែបបទនៃកិច្ចការពាររបស់ក្រុមប្រឹក្សាយុវជនកម្ពុជា ត្រូវបានរៀបរៀងឡើងក្នុងគោលបំណងដើម្បីការពារកុមារពីទុក្ខភ័យ និងដើម្បីធ្វើការណែនាំដល់បុគ្គលិក អ្នកផ្តល់ជំនួយ និងអ្នកពាក់ព័ន្ធនឹងកុមារដទៃទៀត ដើម្បីឱ្យគេធ្វើការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពជាមួយកុមារទាំងឡាយ។

## ៣. ការរំលោភបំពានកុមារ

តើអ្វីទៅជាការរំលោភបំពានកុមារ និងការមិនយកចិត្តដាក់ចំពោះកុមារ?[២]

ដើម្បីស្របតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ នៅក្នុងច្បាប់នេះពាក្យកុមារ គឺមនុស្សទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ។

ពាក្យថាការរំលោភបំពាន ត្រូវបានឱ្យនិយមន័យថា ជាសកម្មភាពដែលធ្វើឡើងដោយឪពុកម្តាយ អ្នកថែរក្សា មនុស្សពេញវ័យ ឬមនុស្សពេញជំទង់ និងកុមារដែលមានអាយុលើសកុមាររងគ្រោះ ៥ឆ្នាំ ដែលធ្វើឱ្យមានគ្រោះថ្នាក់ផ្លូវកាយ ផ្លូវចិត្ត ការបំពានលើផ្លូវភេទ ការប្រមាថ ការធ្វេសប្រហែសមិនយកចិត្តទុកដាក់ថែទាំ ឬការធ្វើពាណិជ្ជកម្ម ឬការកេងប្រវ័ញ្ចផ្សេងៗទៀត និងការវិវត្តន៍របស់កុមារការរស់នៅ ការអភិវឌ្ឍ ឬសេចក្តីថ្លៃថ្នូរ នៅក្នុងបរិបទស្តីពីទំនាក់ទំនង នៃការទទួលខុសត្រូវ ភាពជឿជាក់ ឬអំណាច។

២ និយមន័យនៃពាក្យ «រំលោភបំពាន» ត្រូវបានដកស្រង់ចេញពីវិទ្យាស្ថានសិក្សាគ្រួសារ ការិយាល័យនៃការការពារកុមារជាតិ និងការរំលោភបំពានលើកុមារ របស់ WHO ដែលបានកំណត់តាមរយៈរបាយការណ៍ស្តីពីការប្រឹក្សាយោបល់លើការការពារ ការបំពារបំពានលើកុមារ WHO-១៩៩៩។

## ៤. ការអនុវត្តគោលនយោបាយ

នាយក/នាយិកាប្រតិបត្តិ សមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងរបស់ក្រុមប្រឹក្សាយុវជនកម្ពុជា មានតួនាទីក្នុងការទទួលខុសត្រូវ ក្នុងការលើកកម្ពស់គាំទ្រសិទ្ធិកុមារ និងត្រូវនាំមុខឱ្យបានជោគជ័យ។ ក្នុងករណីដែល នាយក/នាយិកាប្រតិបត្តិរបស់ក្រុមប្រឹក្សាយុវជនកម្ពុជា ដែលមានជាប់ពាក់ព័ន្ធនៅក្នុងការរំលោភបំពាននោះ សមាជិកក្រុមប្រឹក្សាភិបាល មានសិទ្ធិបង្កើតគណៈកម្មាការដើម្បីស៊ើបអង្កេតលើករណីនោះ។ ក្រុមគណៈកម្មាធិការគ្រប់គ្រងនឹងត្រូវទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងធានាទៅលើការអនុវត្តច្បាប់។

### ៤.១. សីលធម៌ផ្ទាល់របស់បុគ្គលិកក្រុមប្រឹក្សាយុវជនកម្ពុជា

- ត្រូវបង្កលក្ខណៈ និងបង្កឱ្យមានបរិយាកាសមួយដែលមានសុវត្ថិភាពសម្រាប់កុមារ ក្នុងការចូលរួមសកម្មភាពផ្សេងៗ របស់ក្រុមប្រឹក្សាយុវជនកម្ពុជា។
- ត្រូវរាប់រក និងរាប់អានកុមារក្នុងលក្ខណៈមួយ ដែលបង្ហាញឱ្យឃើញពីការគោរព និងការគួរសម។
- ត្រូវដឹងពីទំនាក់ទំនងទៅវិញទៅមករបស់បុគ្គលិក ក្រុមប្រឹក្សាយុវជនកម្ពុជា ជាមួយកុមារ ថាតើកុមារផ្ទាល់ និងអ្នកដទៃយល់ឃើញយ៉ាងណាចំពោះទំនាក់ទំនងនេះ។
- ត្រូវរាយការណ៍ភ្លាមៗ អំពីការចោទប្រកាន់ ឬពីការសង្ស័យផ្សេងៗទាក់ទងនឹងការរំលោភបំពានកុមារ។
- ត្រូវធ្វើការដោះស្រាយឱ្យបានឆាប់រហ័ស និងដោយសម្ងាត់នូវគ្រប់ការចោទប្រកាន់ទាំងឡាយដែលមានពាក់ព័ន្ធនឹងកុមារ។
- ត្រូវចាត់ទុកសុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់កុមារជាបញ្ហាសំខាន់បំផុត។
- ត្រូវទទួលស្គាល់ថា ខ្លួនជាភាគីដែលត្រូវទទួលខុសត្រូវជាប់ជានិច្ច ទោះបីជាកុមារមានអា កប្បកិរិយាមិនសមរម្យក៏ដោយ។
- មិនរើសអើងចំពោះកុមារណាឡើយ។
- មិនប្រើប្រាស់សិទ្ធិរបស់ខ្លួនមិនសមរម្យឡើយ។
- មិនត្រូវធ្វើអាកប្បកិរិយាអ្វីមួយ (កាយវិការ ពាក្យសម្តី ឬអ្វីទៀត) ដែលមើលទៅឃើញថាជាការមើលងាយ មិនសមរម្យ ដែលពេញដោយការរំលោភបំពាន ការធ្វេសប្រហែស ឬពោរពេញដោយការកេងផលប្រយោជន៍។

- បុគ្គលិក ក.យ.ក មិនត្រូវផ្តល់ផ្ទះ សម្រាប់ឱ្យកុមារមកជ្រកកោនឡើយ លើកលែងតែមានការបន្ទាន់ខ្លាំងបំផុត។
- បើសិនជាអាចធ្វើបាន មិនត្រូវចំណាយពេលស្ងាត់ៗជាមួយកុមារតែ ២នាក់ ដែលមិនមែនជាសមាជិកក្នុងគ្រួសារ ដែលជាសាច់ញាតិជិត ឬសាច់ញាតិឆ្ងាយរបស់បុគ្គលិក ក.យ.ក នៅកន្លែងធ្វើការ ឬនៅកន្លែងណាផ្សេងទៀតឡើយ។

## ៤.២ ការជ្រើសរើសបុគ្គលិក

- ការប្តេជ្ញា របស់ក្រុមប្រឹក្សាយុវជនកម្ពុជា ក្នុងកិច្ចការពារកុមារត្រូវបានបញ្ជាក់យ៉ាងច្បាស់តាមរយៈគោលការណ៍ដ៏ហ្មត់ចត់ ទាក់ទងនឹងការជ្រើសរើសបុគ្គលិកជាពិសេសបុគ្គលិកទាំងឡាយណាដែលនឹងត្រូវមានការទំនាក់ទំនងផ្ទាល់ជាមួយកុមារ។
- បុគ្គលិកទាំងឡាយ របស់ក្រុមប្រឹក្សាយុវជនកម្ពុជា នឹងត្រូវបានគេពន្យល់ឱ្យដឹងច្បាស់ពីច្បាប់ និងទម្រង់បែបបទនៃកិច្ចការពារកុមារ នៅក្នុងកំឡុងពេលនៃការណែនាំការងារ។
- បុគ្គលិកនឹងត្រូវចុះហត្ថលេខាទទួលដឹងឮថាពួកគេបានអាន និងធ្វើតាមនូវតម្រូវការផ្សេងៗដែលមានចែងនៅក្នុងច្បាប់។
- គ្រប់បុគ្គលិកក្រុមប្រឹក្សាយុវជនកម្ពុជានឹងត្រូវស៊ើបប្រវត្តិនៃបទឧក្រិដ្ឋទៅតាមរយៈការបញ្ជាក់ពីលិខិតថ្កោលទោស ដែលចេញដោយក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា។
- ការស៊ើបអង្កេតនេះ នឹងធ្វើឡើងនៅពេលដែលបុគ្គលិកចាប់ផ្តើមធ្វើការជាមួយអង្គការ ហើយបន្ទាប់មកនឹងមានការស៊ើបអង្កេតរៀងរាល់ ២ឆ្នាំម្តង។
- ត្រូវទទួលបាននូវការស៊ើបប្រវត្តិ អត្តចរិតផ្ទាល់ខ្លួនពីអ្នកពាក់ព័ន្ធដែលស្គាល់យ៉ាងហោចណាស់ ២នាក់។
- ក្រុមប្រឹក្សាយុវជនកម្ពុជាមិនជ្រើសរើសអ្នកណាម្នាក់ដែលត្រូវបានផ្តន្ទាទោសថាមានប្រព្រឹត្តបទឧក្រិដ្ឋទាក់ទងនឹងកុមារឡើយ។
- មន្ត្រីរដ្ឋបាល និងហរិញ្ញវត្ថុ មានតួនាទីទទួលខុសត្រូវ ក្នុងការចាត់ចែងការងារនៃការស៊ើបពិនិត្យប្រវិត្តនៃបទឧក្រិដ្ឋ និងការណែនាំស្តីពីគោលនយោបាយនេះដល់បុគ្គលិកថ្មីទាំងអស់។

## ៥. ការបណ្តុះបណ្តាល

ដើម្បីឱ្យកម្មវិធីមានគុណភាពល្អ បុគ្គលិកទាំងអស់ នឹងតម្រូវឱ្យមានការរៀបចំវគ្គបណ្តុះបណ្តាលបន្ថែមទាក់ទងនឹងកិច្ចការពារកុមារ និងធ្វើការងារជាមួយកុមារ។

## ៦. ការផ្សព្វផ្សាយ និងការទំនាក់ទំនង

ហាមដាច់ខាតមិនត្រូវយកព័ត៌មាន ឬ រូបភាពផ្សេងៗរបស់កុមារទៅផ្សព្វផ្សាយក្នុងសារព័ត៌មាន ណាមួយដោយមិនមានគោលការណ៍នៃការប្រើប្រាស់រូបភាពនេះច្បាស់លាស់ឡើយ

(មិនមានការអនុញ្ញាតសិទ្ធិពីអាណាព្យាបាលរបស់កុមារដែលពាក់ព័ន្ធ) មិនថាការផ្សព្វផ្សាយនោះ តាមរយៈសារអេឡិចត្រូនិច ឬផ្តិតចេញលើក្រដាសរូបភាពក្តី។

គ្រប់ការទំនាក់ទំនងផ្សេងៗ ដែលទាក់ទងនឹងការប្រើប្រាស់រូបភាពរបស់កុមារ និងអត្ថបទដែលស្តីអំពីកុមារ នឹងត្រូវប្រើប្រាស់ដោយគិតដល់ភាពថ្លៃថ្នូរ និងការគោរពដល់កុមារ។ គ្រប់រូបភាពទាំងឡាយដែលត្រូវយកមកប្រើប្រាស់ក្នុងឯកសារនៃការទំនាក់ទំនង គឺប្រើតែរូបភាពណាដែលដែលមិនមានលក្ខណៈធ្វើឱ្យឈឺចាប់ដល់កុមារឡើយ ហើយជៀសវាងថតរូបណាដែលមើលទៅហាក់ដូចជាមិនសមរម្យខាងផ្លូវភេទ។

បើប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុង ឬការប្រព្រឹត្តល្មើស និងទម្រង់បែបបទនៃកិច្ចការពារកុមារ នោះ នឹងមានការចាត់វិធានការឱ្យកែប្រែខ្លួន ដែលអាចក្លាយជាករណីដែលត្រូវបញ្ឈប់ពីការងារបាន និងដែលអាចក្លាយជាករណីរឿងក្តីដោយការចោទប្រកាន់ទៅតាមផ្លូវច្បាប់ដែរ។ បើមានការប្រព្រឹត្តល្មើសនឹង «គោលសីលធម៌» ដូចបានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងនេះ គឺត្រូវចាត់ទុកថាជាករណីល្មើសនៃអសីលធម៌ ហើយនឹងត្រូវបញ្ឈប់ពីការងារ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១... ខែ ..៥...... ឆ្នាំ២០១៨

ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិក

# សេចក្តីថ្លែងការណ៍នៃការប្តេជ្ញាចិត្ត
# នៅលើគោលការនយោបាយការពារកុមារ របស់ក្រុមប្រឹក្សាយុវជនកម្ពុជា

ខ្ញុំ, ..................................................., បានអាន និងបានយល់ពីគោលនយោបាយក្នុងការគាំពារកុមារនេះ។ ខ្ញុំយល់ព្រមជាមួយនឹងគោលការណ៍ដែលមានចែងនៅក្នុងនោះ ព្រមទាំងយល់ស្របចំពោះអំពីសារសំខាន់នៃការអនុវត្តគោលនយោបាយការពារកុមារ និងការអនុវត្តតាម ខណៈ ដែលធ្វើការជាមួយក្រុមប្រឹក្សាយុវជនកម្ពុជា។ ខ្ញុំបានយល់ថា ប្រសិនមានពាក្យបណ្តឹងណាមួយត្រូវបានធ្វើឡើងចំពោះការរំលោភបំពានលើកុមារ ទោះតាមលក្ខណៈបែបណាមួយក៏ដោយ ក៏នៅពេលដែលចូលរួមសកម្មភាពជាមួយក្រុមប្រឹក្សាយុវជនកម្ពុជា ការចោទប្រកាន់នោះនឹងត្រូវបានធ្វើការស៊ើបអង្កេតយ៉ាងហ្មត់ចត់បំផុតក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងរដ្ឋអំណាចនានាដែលសមស្រប៕

ឈ្មោះ ..........................................................

តួនាទីភារកិច្ច/មុខតំណែង ....................................

ហត្ថលេខា ......................................................

កាលបរិច្ឆេទ ..................................................